# ការសិក្សា ការអភិវឌ្ឍន៍ទឹកក្រោមដីក្នុងភាគកណ្ដាលនៃប្រទេសកម្ពុជា

## របាយការណ៍ព្រាងបញ្ចប់

## របាយការណ៍សង្ខេប

ទីតាំងក្នុងផែនទី

ពាក្យបំព្រួញ

ខ្លឹមសារសង្ខេប

# មាតិការ

## ជំពូក១ សេចក្ដីផ្ដើម


1.1 ប្រវត្តិសង្ខេប ........ 1-1

1.2 គោលបំណងការសិក្សា និង ទំហំការងារ ........ 1-2

1.2.1 គោលបំណង ........ 1-2

1.2.2 ទំហំការងារ ........ 1-2

1.3 តំបន់សិក្សា ........ 1-3


## ជំពូក២ បរិស្ថានធម្មជាតិ


2.1 អាកាសធាតុ ........ 2-1

2.2 ភូគព្ភសាស្ត្រ និងដ្ឋានលេខាសាស្ត្រ ........ 2-1

2.3 ជលសាស្ត្រ ........ 2-2


## ជំពូក៣ សេដ្ឋកិច្ចសង្គម និងការផ្គត់ផ្គង់ទឹក


3.1 លក្ខខណ្ឌសេដ្ឋកិច្ចសង្គមជាតិ ........ 3-1

3.1.1 ប្រជាជន និងតំបន់ ........ 3-1

3.1.2 ប្រព័ន្ធរដ្ឋបាល ........ 3-1

3.1.3 សេដ្ឋកិច្ច ........ 3-1

3.2 សេដ្ឋកិច្ចសង្គមនៃតំបន់សិក្សា ........ 3-2

3.2.1 សកម្មភាពសេដ្ឋកិច្ច ........ 3-2

3.2.2 សាលារៀន និង មន្ទីរពេទ្យ ........ 3-3

3.2.3 ការផ្គត់ផ្គង់ទឹក ........ 3-3

3.2.4 ផ្លូវ ....................................................................................................................3-4
3.2.5 គណៈកម្មការអភិវឌ្ឍន៍ភូមិ ........................................................................................3-4
3.3 ការផ្គត់ផ្គង់ទឹកនៅតាមជនបទ ...........................................................................................3-5
3.3.1 ប្រព័ន្ធផ្គត់ផ្គង់ទឹកនៅតាមជនបទ ...............................................................................3-5
3.3.2 ថវិការផ្គត់ផ្គង់ទឹកជនបទ .......................................................................................3-6
3.3.3 សមិទ្ធិផលការផ្គត់ផ្គង់ទឹកជនបទ ................................................................................3-7
3.3.4 គំរោងផ្គត់ផ្គង់ទឹករយៈពេល ៥ឆ្នាំ .................................................................................3-8
3.4 លក្ខខណ្ឌ សុខភាព និង អនាម័យ ...................................................................................3-9

## ជំពូក៤ ការអង្កេតទឹកក្រោមដី

4.1 លក្ខណៈអ៊ីដ្រូសែន ...........................................................................................................4-1
4.1.1 លក្ខណៈអ៊ីដ្រូសែន ..................................................................................................4-1
4.1.2 ឯកត្តាអ៊ីដ្រូសែន.....................................................................................................4-2
4.1.3 ការខួងអណ្តូងសាកល្បង ...........................................................................................4-3
4.1.4 វត្តមាននៃស្រទាប់ថ្មដែលមានប្រភពទឹកពីក្រោម..............................................................4-3
4.2 កំរិតទឹកក្រោមដី ..............................................................................................................4-10
4.3 គុណភាពទឹកក្រោមដី .......................................................................................................4-20
4.4 ការវាយតំលៃធនធានទឹកក្រោមដី ........................................................................................4-53
4.4.1 ផែនទីវារីភូគព្ភសាស្ត្រ ..................................................................................................4-53
4.4.2 ការវាយតំលៃបរិមាណ ...............................................................................................4-53
4.4.3 ការវាយតំលៃគុណភាព ..............................................................................................4-53
4.5 ការវិភាគតុល្យភាព ..............................................................................................................4-54

## ជំពូក៥ ការសិក្សាអង្កេតស្រាវជ្រាវ

5.1 ការជ្រើសរើសភូមិគោលដៅ ...............................................................................................5-1
5.1.1 ភូមិស្នើសុំ .............................................................................................................5-1
5.1.2 ដំណើរការជ្រើសរើស និងលក្ខណៈវិនិច្ឆ័យទៅលើភូមិគោលដៅ ......................................5-2
5.2 ការសិក្សាស្រាវជ្រាវចំនួន ៣០៣ភូមិគោលដៅ.........................................................................5-2
5.2.1 គោលបំណង និង វិធិសាស្ត្រ ........................................................................................5-2
5.2.2 ស្ថានភាពសេដ្ឋកិច្ចសង្គម .........................................................................................5-3
5.2.3 ស្ថានភាពផ្គត់ផ្គង់ទឹក ...............................................................................................5-7

5.2.4 ការប្រើប្រាស់ និងថែរក្សា ........ 5-8

5.2.5 ពត៌មានអំពីការអភិវឌ្ឍន៍ទឹកក្រោមដី ........ 5-9

5.2.6 ស្ថានភាពសុខភាព និងអនាម័យ ........ 5-10

5.3 ការសិក្សាទៅភូមិជាអទិភាព ........ 5-11

5.3.1 វិធីសាស្ត្រក្នុងការប្រើប្រាស់ ........ 5-11

5.3.2 ប្រជាជន និងលក្ខណៈតាំងទីលំនៅ ........ 5-11

5.3.3 ការបង្កើតសហគមន៍, សេវាសាធារណៈ និងផ្លូវថ្នល់ ........ 5-13

5.3.4 សកម្មភាពសេដ្ឋកិច្ចនៅក្នុងភូមិ ........ 5-13

5.3.5 ចំណូលគ្រួសារ ........ 5-14

5.3.6 ស្ថានភាពផ្គត់ផ្គង់ទឹកជនបទ ........ 5-14

5.4 ការវិភាគលើការប្រើប្រាស់អណ្តូងស្នប់ ........ 5-15

5.4.1 គោលបំណង និងវិធីសាស្ត្រ ........ 5-15

5.4.2 លទ្ធផលនៃការអង្កេតស្រាវជ្រាវ ........ 5-16

5.5 ការវិភាគលើភេទ ........ 5-19

5.5.1 ទស្សនៈស្តីពីស្ថានភាពស្ត្រីនៅកម្ពុជា ........ 5-19

5.5.2 ការវិភាគលើភេទ ........ 5-21

**ជំពូក៦ កម្មវិធីចូលរួមរបស់សហគមន៍**

6.1 វិធីសាស្ត្រ និង គោលនយោបាយ ........ 6-1

6.1.1 វិធីសាស្ត្រ ........ 6-1

6.1.2 គោលនយោបាយចូលរួមរបស់សហគមន៍ ........ 6-1

6.2 មធ្យោបាយផ្គត់ផ្គង់ទឹក ........ 6-1

6.3 ការបង្កើតគណៈកម្មាធិការទឹកភូមិ និងគណៈកម្មាធិការចំណុចអណ្តូង ........ 6-3

6.3.1 សកម្មភាពថ្នាក់មជ្ឈឹម និងថ្នាក់ខេត្ត ........ 6-3

6.3.2 សកម្មភាពថ្នាក់ភូមិ ........ 6-3

6.4 ការប្រើប្រាស់ ថែទាំ និងការអប់រំអនាម័យ ........ 6-5

6.4.1 កម្មវិធីអប់រំ ........ 6-5

**ជំពូក៧ ផែនការអភិវឌ្ឍន៍ទឹកក្រោមដី**

7.1 គោលនយោបាយអភិវឌ្ឍន៍ទឹកក្រោមដី ........ 7-1

7.1.1 ភាពខុសគ្នារបស់តំបន់ដោយសារសក្តានុពលទឹកក្រោមដី ....7-1
7.1.2 គោលនយោបាយអភិវឌ្ឍន៍ ....7-2
7.2 ស្រទាប់ថ្មដែលមានទឹកពីក្រោមជាមុខសញ្ញា ....7-5
7.2.1 ស្រទាប់ទឹកក្រោមដី និង ជំរៅខួង ....7-5
7.2.2 ទំហំនៃការអភិវឌ្ឍន៍ ....7-6
7.3 ប្លង់អណ្តូងជាបទដ្ឋាន ....7-6
7.3.1 ជំរៅជាមុខសញ្ញា ....7-7
7.3.2 វិធីសាស្ត្រខួង ....7-7
7.3.3 កិច្ចបញ្ចប់សាងសង់ ....7-7
**ជំពូក៨ ផែនការផ្គត់ផ្គង់ទឹក**
8.1 នយោបាយផែនការផ្គត់ផ្គង់ទឹក ....8-1
8.2 តំបន់គំរោងនិងការជ្រើសរើសភូមិ ....8-2
8.2.1 តំបន់គំរោងជាមុខសញ្ញា ....8-3
8.2.2 ចំណាត់ថ្នាក់នៃភូមិទាំង ៣០៣ ....8-3
8.2.3 ការជ្រើសរើសភូមិជាមុខព្រួញ ....8-4
8.2.4 ប្រភពទឹកផ្លាស់ ....8-4
8.3 បទដ្ឋាននៃប្លង់....8-6
8.3.1 ចំនួនជាបទដ្ឋានសំរាប់ការប្រើប្រាស់ទឹក ....8-6
8.3.2 ការធ្វើគំរោងស្នើសុំទឹក ....8-8
8.3.3 ការជ្រើសរើសស្នប់ដៃ ....8-8
8.3.4 ចំនួនស្នប់ដែលត្រូវការ ....8-8
8.4 បរិក្ខារផ្គត់ផ្គង់ ....8-10
8.5 តំលៃគំរោង ....8-12
8.5.1 លក្ខណការប៉ាន់ស្មាន ....8-12
8.6 ការអនុវត្តន៍ ....8-16
8.6.1 អង្គភាពអនុវត្តន៍ ....8-16
8.6.2 កាលវិភាគអនុវត្តន៍ ....8-16
8.7 ដំណើរការ និងការថែទាំ និងត្រួតពិនិត្យកម្មវិធី ....8-16

8.7.1 គោលការណ៍ O & M ........ 8-16
8.7.2 ប្រពន្ធ័ប្រតិបត្តិ និងការថែទាំ O & M ........ 8-18
8.7.3 តំនៃប្រតិបត្តិ និងការថែរក្សា ........ 8-18
8.7.4 កម្មវិធីត្រួតពិនិត្យ ........ 8-20
8.8 គោលការណ៍ណែនាំនៅក្នុងយុទ្ធនាការអនាម័យ និង O& M ........ 8-21


## ជំពូក៩ ផែនការអប់រំអនាម័យ

9.1 ស្ថានភាពបច្ចុប្បន្ននៃអនាម័យក្នុងភូមិ ........ 9-1
9.2 ស្ថានភាពបច្ចុប្បន្ននៃការអប់រំអនាម័យ ........ 9-1
9.2.1 ការអប់រំអនាម័យនៅសាលា ........ 9-1
9.2.2 គំរោងដែលមានទំនាក់ទំនងសំខាន់ៗ ........ 9-2
9.3 ផែនការអប់រំអនាម័យ ........ 9-2
9.3.1 ភាពចំបាច់នៃការអប់រំអនាម័យ និងឥទ្ធពលទៅលើគំរោង ........ 9-3
9.3.2 គោលនយោបាយអប់រំអនាម័យ ........ 9-3
9.3.3 វិធីអប់រំអនាម័យ ........ 9-4
9.3.4 ប្រពន្ធ័នៃការអនុវត្តន៍ ........ 9-5


## ជំពូក១០ ការវាយតំលៃគំរោង

10.1 ការពិចារណាលើការវាយតំលៃ ........ 10-1
10.1.1 ទិដ្ឋភាពរួម ........ 10-1
10.1.2 ការកើនឡើងនៃអ្នកទទួលផលប្រយោជន៍ក្នុងភូមិដៅទុក ........ 10-1
10.1.3 ការកែប្រែលក្ខខណ្ឌសុខភាព ........ 10-2
10.1.4 លទ្ធផលនៃការសន្សំពេលវេលាសំរាប់ការដងទឹក ........ 10-2
10.2 ការវិភាគហិរញ្ញវត្ថុ ........ 10-2
10.2.1 គំរោងចំណាយហិរញ្ញវត្ថុ ........ 10-2
10.2.2 ប្រភពហិរញ្ញវត្ថុ ........ 10-3
10.2.3 ការប្រមូលទុនមកវិញ សំរាប់ការចំណាយលើកិច្ចដំណើរការ និងថែទាំ ........ 10-3
10.3 ការវាយតំលៃសេដ្ឋកិច្ច ........ 10-4
10.3.1 ការសន្មត់ជាមូលដ្ឋាន ........ 10-4
10.3.2 ការចំណាយសេដ្ឋកិច្ចគំរោង ........ 10-4
10.3.3 អត្ថប្រយោជន៍សេដ្ឋកិច្ច ........ 10-4

10.3.4 ការវិភាគលើការចំណាយ និងអត្ថប្រយោជន៍ ........ 10-5
10.4 ការចាត់ចែង និងការវាយតំលៃស្ថាប័ន ........ 10-5
10.5 ការវាយតំលៃសង្គម និង WID ........ 10-6
10.6 ការវាយតំលៃបរិស្ថានដំបូង ........ 10-7
10.6.1 ការសិក្សាសំរាំង ........ 10-7
10.6.2 ទំហំការងារ ........ 10-8
10.6.3 លទ្ធផលនៃការវាយតំលៃបរិស្ថានដំបូង ........ 10-9
**ជំពូក១១ ការសន្និដ្ឋាន និង អនុសាសន៍**
11.1 ការសន្និដ្ឋាន ........ 11-1
11.1.1 ការអភិវឌ្ឍន៍ទឹកក្រោមដី ........ 11-1
11.1.2 ផែនការផ្គត់ផ្គង់ទឹក ........ 11-2
11.1.3 ការវាយតំលៃគំរោង ........ 11-3
11.1.4 ការពិចារណាលើលក្ខណៈសង្គម / WID និង IEE ........ 11-3
11.2 អនុសាសន៍ ........ 11-4
11.2.1 ការអនុវត្តន៍មុនគំរោង ........ 11-4
11.2.2 ការស្ទាបស្ទង់គុណភាពទឹក វិធានការ និងការគ្រប់គ្រង ........ 11-4
11.2.3 ការជុំការអភិវឌ្ឍន៍ភូមិជាមួយការផ្តោតទៅលើការផ្គត់ផ្គង់ទឹក ........ 11-6

# ជំពូកទី ៨

# ផែនការផ្គត់ផ្គង់ទឹក

# ជំពូកទី៨ ផែនការផ្គត់ផ្គង់ទឹក

## ៨.១ គោលនយោបាយ ផែនការផ្គត់ផ្គង់ទឹក

(១) ដោយពឹងផ្អែកលើលទ្ធផលនៃការសិក្សាអំពីលក្ខខណ្ឌពិតប្រាកដនៃប្រភពធនធានទឹកដែលមានស្រាប់ផែនការផ្គត់ផ្គង់ទឹកដែលជាមុខព្រួញឆ្នាំ ២០០៥ ត្រូវបានគេរៀបចំសំរាប់ភូមិជាមុខព្រួញទាំងឡាយ ។ នៅក្នុងភូមិមុខព្រួញទាំងនោះ ប្រភពទឹកថ្មីៗត្រូវបានគេត្រូវការជាបន្ទាន់ ហើយប្រជាជនបង្ហាញនូវឆន្ទៈយ៉ាងច្បាស់លាស់ ដើម្បីរៀបចំ ដោយឯករាជ្យនូវ VWC និង WPC និងអនុវត្តដំណើរការ និងការថែទាំ (O & M) ។ ប្រព័ន្ធផ្គត់ផ្គង់ទឹករួមមាន អណ្តូងបំពង់ និងអណ្តូងស្នប់ដៃ ។ O & M នឹងត្រូវបានអនុវត្តដោយអ្នកភូមិខ្លួនឯង (VLOM) ការអនុវត្ត និងការ ថែទាំថ្នាក់ភូមិ ។

(២) តំបន់គ្របដណ្តប់ដោយការសិក្សាស្រាវជ្រាវ គឺជាខេត្តកំពង់ឆ្នាំង ដែលស្ថិតនៅលើចំណោទរាប បន្តរហូតដល់ភ្នំភាគខាងលិច និងនៅទំនាបដីល្បាប់ តាមបណ្តោយបឹងទន្លេសាប ។ ចំនួនភូមិដែលស្នើសុំ គឺ ២០៣ ។ ក្នុងចំណោមភូមិ អស់ទាំងនេះ គឺមានភូមិចំនួនតែ ១១២ ដែលជាមុខសញ្ញា ពីព្រោះប្រជាជនជាង ៥០% ពឹងផ្អែកទៅលើអណ្តូងជីកដី ។ ទោះជាយ៉ាងណាក៏ដោយ ក៏សក្តានុពលនៃស្រទាប់ថ្មដែលមានទឹកពីក្រោមចំនួនមួយភាគបួន ដែលស្ថិតនៅក្នុងខេត្តនេះ គឺមានកំរិតទាប ។ ជាទូទៅទឹកក្រោមដីមានជាតិដែកខ្ពស់ ។ ជាតិអាសេនិកមានកំរិតខ្ពស់ជាងតំលៃតាមការណែនាំរបស់ WHO តាមកន្លែង ។ ម្យ៉ាងវិញទៀត តំបន់ដែលមានក្រហែងនិងសំណឹកដោយអាកាសធាតុនៃថ្មក្រោមដីដែល បង្កើតបានជាស្រទាប់ថ្មមានទឹកពីក្រោម ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នផលប្រែប្រួលពីកន្លែងមួយនៅកន្លែងមួយ ហើយកន្លែងខ្លះតែងតែមិនជួបទឹកក្រោមដី ។ ដើម្បីអភិវឌ្ឍន៍ទឹកក្រោមដីនៅក្នុងខេត្តនេះ ចាំបាច់ត្រូវដឹកនាំការស្ទាប ស្ទង់លក្ខណៈភូមិសាស្ត្រធរណី និងភាពខ្ពស់របស់ដីឱ្យបានលំអិត នៅតាមភូមិនីមួយៗ ។ ជាងនេះទៅទៀត ការឈាន ចូលទៅដល់ភូមិមានលក្ខណៈពិបាក ។ ពិចារណាអំពីការលំបាកនានាដែលបង្ហាញខាងលើ ផែនការផ្គត់ផ្គង់ទឹកនេះ ត្រូវ ដកភូមិមុខសញ្ញាចេញនៅក្នុងខេត្តកំពង់ឆ្នាំង ។ នាពេលអនាគត MRD គួរតែដឹកនាំការស៊ើបអង្កេតទឹកក្រោមដីឱ្យបានល្អិតល្អន់យ៉ាងទៅតាមទំរង់ស្នើសុំរបស់ភូមិ និងការអនុវត្តនូវកម្មវិធីអភិវឌ្ឍន៍ទឹកក្រោមដីនីមួយៗ ។

(៣) នៅក្នុងវាលទំនាបដីល្បាប់ តាមបណ្តោយទន្លេសាប និងទន្លេមេគង្គនៅភាគខាងលិចខេត្តកំពង់ចាម ការអភិ

វឌ្ឍន៍ទឹកក្រោមដី គឺមិនអាចធ្វើទៅបាន ពីព្រោះសក្តានុពលទាប ហើយគុណភាពរបស់ទឹកអន់។ ដូច្នេះហើយ ភូមិដែលជា មុខសញ្ញានៅតាមវាលទំនាបដីល្បាប់ត្រូវបានដកចេញពីផែនការ។ នៅពេលអនាគត MRD គួរតែ ជំរុញការអភិវឌ្ឍន៍ នៃប្រភពទឹកឆ្លាស់ ដូចជាស្ទឹង ទឹកភ្លៀង អណ្តូងរាក់ ដោយមានការការពារ និងឧបករណ៍ យកជាតិដែកចេញ។ល។ ម្យ៉ាងវិញទៀត សក្តានុពលនៃទឹកក្រោមដីនៃសេឌីម៉ង់ Plio-Pleistocene និងថ្ម បាសាល់ គឺមានកំរិតខ្ពស់នៅមាត់បឹង ទន្លេមេគង្គនៃភាគខាងលិចខេត្តកំពង់ចាម។ ទោះជាយ៉ាងណាក៏ដោយ អណ្តូងបំពង់ជាច្រើនបានត្រូវគេខួងរួចទៅ ហើយដោយអង្គការអន្តរជាតិមួយចំនួន ដូចជា PRASAL ប្រទេសចិន និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនប្រចាំ តំបន់នេះ។ ជាងនេះទៀត ចំនួនភូមិដែលជាមុខសញ្ញា គឺមានចំនួនតិច ។ ដូច្នេះហើយ ផែនការក៏បានដកតំបន់នេះចេញ។

(៤) ផែនការនេះនឹងត្រូវបានគេអនុវត្តនៅភាគខាងកើតនៃខេត្តកំពង់ចាម ដែលតាំងនៅត្រើយខាងលិចនៃទន្លេ មេគង្គ។ សេឌីម៉ង់ Plio-Pleistocene និងស្រទាប់ថ្មបាសាល់ នៅក្នុងតំបន់នេះ មានសក្តានុពលខ្ពស់ ហើយគុណ ភាពទឹកក្រោមដីល្អ។ មានអណ្តូងជីកដៃជាច្រើននៅក្នុងតំបន់នេះ។ អណ្តូងភាគច្រើនមិនមានគំរបឡើយ មិន មានចាក់បេតុងជុំវិញ និងការការពារឡើយ។ អណ្តូងជីកដៃជាច្រើនឆ្លងមេរោគដោយមេរោគដង្កូវពោះវៀន ដោយគ្មានករណី លើកលែងឡើយ។ ដូច្នេះហើយវាមានលក្ខណៈបន្ទាន់ ដើម្បីធ្វើឱ្យទឹកបរិភោគប្រកបដោយ សុវត្ថិភាព និងស្អាតនៅក្នុងតំបន់នេះ។ ជាងនេះទៅទៀត ស្ពានមួយឆ្លងកាត់ទន្លេមេគង្គ បានត្រូវគេសង់នៅឆ្នាំ ២០០១។ ដោយមានការសម្ពោធ ឱ្យប្រើប្រាស់ស្ពាននេះ និងការជួសជុលឡើងវិញនូវផ្លូវជាតិលេខ ៧ តំបន់នេះ នឹងត្រូវបានអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ផែនការផ្គត់ផ្គង់ទឹក គឺត្រូវចំពេលវេលាល្អបំផុត សំរាប់ការ គិតគូរនេះ ។

(៥) សំរាប់ការប្រើប្រាស់ជានិរន្តភាពនៃបរិក្ខារផ្គត់ផ្គង់ទឹកតាមភូមិ អ្នកភូមិទាំងឡាយគួរតែត្រូវបង្កើតជាដំបូង នូវ VDC បន្ទាប់មករៀបចំ VWC និង WPC ដោយខ្លួនឯង ព្រមទាំងអនុវត្តដោយឯករាជ្យម្ចាស់ការនូវ O & M និងបរិក្ខារ។ ដូច្នេះហើយ សមាសភាពទន់នៃផែនការផ្គត់ផ្គង់ទឹកនឹងរាប់បញ្ចូលគោលការណ៍ណែនាំនៃការបង្កើត VWC និង WPC និងដំណើរការនេះ ហើយស្របតាមការកសាងបរិក្ខារ និងជំនួយនៅក្នុង O & M ដែលត្រូវ អនុវត្តដោយអ្នកភូមិ។ MRD និងនាយកដ្ឋានដែលពាក់ព័ន្ធ គួរតែត្រូវដឹកនាំយុទ្ធនាការផ្នែកអនាម័យ នៅក្រោម កិច្ចសហប្រតិបត្តិការជាមួយគំរោងអភិវឌ្ឍន៍ថ្មីៗដោយ UNICEF និងអង្គការក្រៅរដ្ឋាភិបាលមួយ ចំនួន។

## ៨.២ តំបន់គំរោង និងការជ្រើសរើសភូមិ

### ៨.២.១ តំបន់គំរោងជាមុខព្រួញ

តំបន់ខេត្តកំពង់ឆ្នាំងទាំងមូលសំរាប់ហេតុផលដែលបានបង្ហាញនៅក្នុងផ្នែក ៨.១ (១) និងស្រុកចំនួន ៥ នៅក្នុងខេត្តកំពង់ចាម (កោះសូទិន ស្ទឹងត្រង់ ក្រូចឆ្មា ចំការលើ និងជើងព្រៃ) សំរាប់ហេតុផលដែលមានបង្ហាញនូវចំណុច ៨.២ (២) ត្រូវបានដកចេញពីតំបន់គំរោងជាមុខសញ្ញា។

ដូច្នេះហើយ តំបន់គំរោងជាយុទ្ធសាស្ត្ររួមមាន ស្រុកទាំងប្រាំខាងក្រោមរបស់ខេត្តកំពង់ចាម :

- ស្រុមមេមត់
- ស្រុកពញាក្រែក
- ស្រុកដំបែ
- ស្រុកត្បូងឃ្មុំ
- ស្រុកអូរាំងឪ

### ៨.២.២ ចំណាត់ថ្នាក់នៃភូមិនានា ៣០៣

ការវាយចំណាត់ថ្នាក់មួយត្រូវបានបង្កើតឡើងដូចមានបង្ហាញនៅក្នុងតារាងលេខ ៨.១ ដើម្បីសំរេចយកភូមិ ជាមុខព្រួញសំរាប់ការអនុវត្តន៏គំរោង ។

លក្ខណ:វិនិច្ឆ័យដើម្បីសំរេចនូវលំដាប់ថ្នាក់របស់ភូមិ សំរាបការអនុវត្តន៏ គឺមានដូចខាងក្រោមនេះ :

(១) សក្តានុពលនៃការអភិវឌ្ឍន៏ទឹកក្រោមដី ដោយពឹងផ្អែកលើបរិមាណ

(២) សក្តានុពលនៃការអភិវឌ្ឍន៏ទឹកក្រោមដី ដោយពឹងផ្អែកទៅលើគុណភាព

(៣) ការឈានចូលដល់ការដ្ឋាន

(៤) លក្ខខណ្ឌទឹកជំនន់

(៥) ចំនួនស្នប់ដៃដែលមានស្រាប់ (បង្កើតបទដ្ឋានមួយនៃម៉ាស៊ីនបូមមួយ ក្នុងចំណោមប្រជាជនចំនួន ២១០) យោលទៅតាមជំពូកទី ៨.៣ ។

(៦) វត្តមាននៃអណ្តូងស្នប់ដៃដែលមានស្រាប់

(៧) វត្តមាននៃ **VDC** (គណ:កម្មាធិការអភិវឌ្ឍន៏ភូមិ)

## ៨.២.៣ ការជ្រើសរើសភូមិជាមុខសញ្ញា

លទ្ធផលនៃចំណាត់ថ្នាក់ដែលពឹងផ្អែកទៅលើគោលនយោបាយរបស់គំរោង និងលទ្ធផលនៃការស្ទាបស្ទង់តាម ភូមិត្រូវបានបង្ហាញនៅក្នុងតារាង ៨.១។ ភូមិចំនួន ១៣១ មានលំដាប់ថ្នាក់ ក ខ គ និង ឃ ដែលសក្តានុពលនៃការអភិវឌ្ឍន៍ទឹកក្រោមដី និងសេចក្តីត្រូវការសំរាប់ការសាងសង់អណ្តូង គឺមានលក្ខណៈធំធេងត្រូវបានរៀបចំជាផែនការជាភូមិមុខសញ្ញា។

តារាង ៨.១ លំដាប់ថ្នាក់ភូមិសំរាប់ការអនុវត្តន៍គំរោង

| លំដាប់ថ្នាក់ | ចំនួនភូមិជាមុខសញ្ញា | | |
|---|---|---|---|
| | ខេត្តកំពង់ឆ្នាំង | ខេត្តកំពង់ចាម | សរុប |
| ក | 0 | ២៨ | ២៨ |
| ខ | 0 | ៥៥ | ៥៥ |
| គ | 0 | ២០ | ២០ |
| ឃ | 0 | ២៨ | ២៨ |
| សរុប | 0 | ១៣១ | ១៣១ |
| ង | 0 | ១១ | ១១ |
| ច | 0 | ១៣ | ១៣ |
| ឆ | 0 | ៦ | ៦ |
| ជ | 0 | ២ | ២ |
| ឈ | 0 | ២៨ | ២៨ |
| ញ | ១១.២ | 0 | ១១៣ |
| សរុប | ១១២ | ១៩១ | ៣០៣ |

## ៨.២.៤ ប្រភពទឹកផ្លាស់

ការប្រើប្រាស់ប្រភពទឹកធ្លាស់នៅក្នុងភូមិចំនួន ១៧២ (ក្នុងចំណោម ៣០៣) ដែលត្រូវដកចេញពីភូមិជាមុខ ព្រួញសំរាប់ការអនុវត្តន៍គំរោង និងត្រូវការឱ្យគេត្រួតពិនិត្យ។ ការប្រើប្រាស់ជាសក្តានុពល និងបញ្ហាដែលជាប្រភពទឹក ធ្លាស់ គឺមានបង្ហាញខាងក្រោម។

(១) អណ្តូងជីកចំនួនប្រភពទឹកជាមួយសក្តានុពលសំរាប់ការប្រើប្រាស់មានបង្ហាញនៅក្នុងតារាងលេខ ៨.២។ មានអណ្តូងជាមធ្យម ២៩.៥ អណ្តូងជីកដែលបានប្រើប្រាស់ក្នុងភូមិមួយនៅក្នុងរដូវប្រាំង ហើយអណ្តូងអស់ទាំងនេះប្រើប្រាស់ជាប្រភពទឹកដ៏ច្រើនបំផុត ក្នុងចំណោមប្រជាជនទាំងឡាយ។ ជាងនេះទៅទៀត ដោយសារអណ្តូងជីកមាននៅ គ្រប់ភូមិទាំងអស់លើកលែងតែភូមិចំនួន ៥ ក្នុងចំណោមភូមិ ៣០៣ គេបានពិចារណាថាការអភិវឌ្ឍន៍អណ្តូងជីក គឺ អាចមានលទ្ធផលនៅក្នុងភូមិទាំងមូល។

បញ្ហាដែលសំខាន់ជាមួយអណ្តូងជីក គឺថា ទឹកនោះប្រែក្លាយទៅជាឆ្លងរោគដោយការលាមកហូរចូល និងការជ្រាបទឹកចូល។ នៅក្នុងស្ថានភាពបែបនេះ បញ្ហាត្រូវបានដោះស្រាយដោយការអប់រំអ្នក ភូមិអំពីសារៈ សំខាន់នៃការបរិភោគទឹកដាំពុះ។ បញ្ហាមួយទៀត គឺថា ការវិភាគអំពីគំរូរបស់ទឹកដែលយកពីអណ្តូងជីកដែល មានបង្ហាញឱ្យឃើញនូវមេរោគចំលង ក្រៅពីកាកលាមកជាមួយក៏វិតលើសពីគោលការណ៍ណែនាំរបស់ WHO និងការវិសុទ្ធទឹកនៅថ្នាក់ភូមិ នឹងមានការលំបាក។

(២) ទឹកភ្លៀង

ដោយយោលទៅតាមលទ្ធផលនៃការស្ទាបស្ទង់តាមភូមិ ការប្រើប្រាស់ទឹកភ្លៀងជាប្រភពទឹកមួយ គឺជាការប្រតិបត្តិតាមលក្ខណៈប្រពៃណី ហើយទឹកភ្លៀងនេះត្រូវបានគេប្រើ ៨៣% នៃភូមិ ។ គុណភាពទឹកភ្លៀង គឺល្អ និងប្រសិនបើការអប់រំសាធារណៈនៅលើការប្រតិបត្តិអនាម័យត្រូវបានផ្តល់ឱ្យនោះ វាគឺជាប្រភពទឹកធ្លាស់មួយប្រកបដោយសុវត្ថិភាព។ បញ្ហានេះ គឺថា វាគឺមានលក្ខណៈពិបាក ដើម្បីធ្វើឱ្យការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ប្រកបដោយសុវត្ថិ ភាព នៅក្នុងបរិមាណក្នុងរយៈពេលរដូវប្រាំង។

(៣) ទន្លេ

ដោយសារមានទន្លេមួយចំនួនតូចដែលមានទំហំតូច និងមធ្យម នៅជុំវិញភូមិនានា ហើយទន្លេនោះរីងស្ងួតនៅក្នុង

រដូវប្រាំង ហេតុនេះទន្លេពិបាកនឹងប្រើប្រាស់ជាប្រភពទឹកឆ្លាស់ដ៏មានប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ ទន្លេមេគង្គដ៏ធំល្បីងល្បើយហូរចូលនៅក្នុងខេត្តកំពង់ចាម និងទន្លេសាប នៅក្នុងខេត្តកំពង់ឆ្នាំង ហើយទោះបីជាកំរិតទឹករបស់ទន្លេធ្លាក់ចុះក៏ដោយ ក៏ទន្លេទាំងពីរនេះអាចត្រូវបានគេប្រើប្រាស់ពេញមួយឆ្នាំជាប្រភពទឹក។ នៅក្នុងតំបន់មួយ ដែលគុណភាពទឹកអណ្ដូងជីកគ្មានសុវត្ថិភាព ហើយប្រភពទឹកឆ្លាស់មានលក្ខណៈពិបាកក្នុងការផ្ដល់សុវត្ថិភាពនៅក្នុងរដូវប្រាំង វិធានការដ៏មានប្រសិទ្ធភាពមួយ គឺត្រូវតែកសាងប្រព័ន្ធផ្គត់ផ្គង់ទឹកតាមបណ្ដាញលូ ដោយប្រើប្រាស់សាងសង់តំរោង នេះមានកំរិតខ្ពស់ ការសិក្សាអំពីលទ្ធភាពមួយត្រូវបានគេត្រូវការ។

## ចំនួនជាមធ្យមនៃប្រភពទឹកដែលអាចមាននៅក្នុងភូមិ




**រូបភាពលេខ ៨.២ ចំនួនជាមធ្យមនៃប្រភពទឹកដែលអាចមាននៅក្នុងភូមិ**

## ៨.៣ មូលដ្ឋាននៃប្លង់

### ៨.៣.១ ចំនួនជាមូលដ្ឋានសំរាប់ការប្រើប្រាស់ទឹក

លទ្ធផលនៃការស្ទាបស្ទង់តាមភូមិបង្ហាញថា ការប្រើប្រាស់ទឹកជាមធ្យមនៅក្នុងភូមិជាមុខព្រួញ គឺ ១៥២ លីត្រក្នុងមួយផ្ទះ (ចូរមើលតារាង ៨.២) ។

MRD មិនបានបង្កើតនូវចំនួនជាបទដ្ឋាមួយសំរាប់ការប្រើប្រាស់ទឹកសំរាប់ការផ្គត់ផ្គង់ទឹកនៅជនបទឡើយ ក្នុងការអនុម័យពី ២០លីត្រ / ម្នាក់ / ថ្ងៃ ដោយពឹងផ្អែកទៅលើបទដ្ឋានរបស់ WHO នានានៅក្នុងតារាង ៨.៣។ ទោះជាយ៉ាងណាក៏ដោយ តួលេខនេះប្រែប្រួលយ៉ាងខ្លាំងពីភាពពិតទៅតាមការពិចារណានៃភាពត្រឹមត្រូវនៃការស្ទាបស្ទង់តាមភូមិ។ ដូច្នេះគំរោងនេះសំរេចទៅតាមកំរិតខាងលើរបស់ WHO នៃចំនួន ៤០លីត្រ / ម្នាក់ / ថ្ងៃ សំរាប់ការ ផ្គត់ផ្គង់ទឹកនៅជនបទ ។

## តារាង ៨.២ ចំនួនប្រើប្រាស់ទឹក (ឯកតា : លីត្រ / ម្នាក់ / ថ្ងៃ )

| គោលបំណង | រដូវវស្សា | រដូវប្រាំង | ជាមធ្យម |
|---|---|---|---|
| ទឹកផឹក | ២,២ | ៣,១ | ២,៦ |
| ចំអិនអាហារ | ៨,២ | ៩,០ | ៨,៨ |
| ងូត | ៦០,២ | ៧៥,២ | ៦៧,៦ |
| បោកគក់ | ២៦,៤ | ២៦,៩ | ២៦,៦ |
| ស្រោចស្ពួន | ៦,៣ | ៣៦,៨ | ២១,៦ |
| សត្វ | ៩,៣ | ៣៥,៥ | ២២,៤ |
| ដទៃទៀត | ២,៤ | ២,៤ | ២,៤ |
| សរុប | ១១៥,៤ | ១៨៨,៨ | ១៥២,១ |

## តារាង ៨.៣ បទដ្ឋានរបស់ WHO នៃចំងាយទៅប្រភពទឹក

| ប្រភពទឹក | ចំងាយ | ចំនួនជាបទដ្ឋាននៃការប្រើប្រាស់ទឹក |
|---|---|---|
| ចំងាយទៅប្រភពទឹក | > ១០០ ម៉ែត្រ<br>៥០០ - ១០០០ ម៉ែត្រ | ៥ - ១០ លីត្រ / ម្នាក់ / ថ្ងៃ<br>១០ - ១៥ លីត្រ / ម្នាក់ / ថ្ងៃ |
| ចំងាយទៅអណ្តូងភូមិ | > ២៥០ ម៉ែត្រ<br>< ២៥០ ម៉ែត្រ | ១៥ - ២៥ លីត្រ / ម្នាក់ / ថ្ងៃ<br>២០ - ៤០ លីត្រ / ម្នាក់ / ថ្ងៃ |
| កាលទឹកជាសាធារណៈ | | ៥០ លីត្រ / ម្នាក់ / ថ្ងៃ |

## ៨.៣.២ ការធ្វើគំរោងស្នើសុំទឹក

ដោយយោលទៅតាមលទ្ធផលនៃការស្ទាបស្ទង់តាមភូមិ អត្រាកើនឡើងប្រចាំឆ្នាំនៃភូមិចំនួន ៣០៣ គឺ ០,៩% នៅខណៈដែលអត្រាកើនឡើងប្រចាំឆ្នាំនៃភូមិ ដោយគ្មានផ្ទះសម្បែងដែលត្រូវវិចូល / ចេញ គឺ ២,២៣ % (ចូរមើលតារាង ៥.២.៣.៤)។ តាមការពិចារណាអំពីភាពពិតនៃការរីកចំរើនអត្រាប្រជាជនពិតចំនួន ២,២៣% នឹង ត្រូវបានអនុម័យ។ ពឹងផ្អែកទៅលើអត្រាប្រជាជនប្រចាំតំបន់សិក្សាដែលបានធ្វើគំរោងសំរាប់ឆ្នាំង ២០០៥ (អត្រាកើនចំនួន ២,២៣%) អត្រាប្រជាជននៃភូមិជាមុខព្រួញចំនួន ១៣១ នឹងកើនឡើងដល់ចំនួនសរុបមួយនៃ ១១៨៣២០ នាក់។ ការស្នើសុំទឹកដែលបានប៉ាន់ស្មាន ជាលទ្ធផលនៃការកើនឡើងនេះ គឺមានបង្ហាញនៅក្នុង តារាង ៨.៤ ។

### តារាង ៨.៤ អត្រាប្រជាជន និងព្យាករណ៍នៃការត្រូវការទឹកក្នុងភូមិមុខព្រួញចំនួន ១៣១

| ខេត្ត | ចំនួនភូមិ | អត្រាប្រជាជន ២០០១ | អត្រាប្រជាជន ២០០៥ | ត្រូវការទឹក $m^3$ / ថ្ងៃ ៤០លីត្រ/ម្នាក់/ថ្ងៃ |
|---|---|---|---|---|
| កំពង់ឆ្នាំង | 0 | 0 | 0 | 0 |
| កំពង់ចាម | ១៣១ | ១០៨៣៣២ | ១១៨៣២០ | ៤៧៣៣ |
| សរុប | ១៣១ | ១០៨៣៣២ | ១១៨៣២០ | ៤៧៣៣ |

## ៨.៣.៣ ការជ្រើសរើសស្នប់ដៃ

ដោយយោលទៅតាមលទ្ធផលនៃការប្រៀបធៀបស្នប់ដៃដែលបានបង្ហាញនៅក្នុង ៦.២ បទពិសោធន៍នៃ បរិក្ខារផ្គត់ផ្គង់ទឹកនៅក្នុងការសិក្សា និងការសិក្សាអំពីការអភិវឌ្ឍន៍ទឹកក្រោមដី នៅក្នុងភាគខាងត្បូងប្រទេសកម្ពុជា ស្នប់បូមដៃ **Afridev** គឺជាស្នប់បូមដៃដ៏ល្អបំផុតនៅក្នុងប្រទេសកម្ពុជា យើងនឹងត្រូវបានគេអនុម័យសំរាប់គំរោងប្រតិបត្តិ។

## ៨.៣.៤ ការជ្រើសរើសស្នប់ដៃ

សមត្ថភាពបូមរបស់ស្នប់បូមដៃ **Afridev** ប្រែប្រួលដោយយោងទៅតាមការលេចជ្រាប មេគុណ និងកំរិតទឹកក្រោមដី។ ម្យ៉ាងវិញទៀត ការស្ទាបស្ទង់នៅតាមការដ្ឋានបង្ហាញពីបរិមាណបូមពិតប្រាកដនៃចំនួន ១៥ ទៅ ២០ លីត្រ / នាទី។ ដូច្នេះគំរោងនេះ មានផែនការបូមទឹកជាមធ្យមចំនួន ១៧,៥លីត្រ / នាទី សំរាប់រយៈពេល៨ម៉ោង ។ ជាមួយស្នប់បូមដៃ។ ចំនួនបូមជាមុខសញ្ញាក្នុងស្នប់បូមដៃមួយនឹងមានចំនួន 8/4 $m^3$ / ថ្ងៃ ៤០លីត្រ / ម្នាក់ / ថ្ងៃ និងប្រជាជនចំនួន ២១០ តាមការមើលឃើញ។

នៅក្នុងខណៈដែលចំនួនស្នប់បូមដៃត្រូវបានគេគ្រោងចំនួន ២០-២៥ ផ្ទះ សំរាប់ស្នប់បូមដៃមួយតាមកម្មវិធី **"Seth Koma Progarm"** ( **UNICEF** ឆ្នាំ២០០១-២០០៥) ដោយយោលទៅតាមរបាយការណ៍ត្រួតពិនិត្យរីកចំរើននៃការសិក្សាលើការអភិវឌ្ឍន៍ទឹកក្រោមដី នៅក្នុងប្រទេសកម្ពុជាភាគខាងត្បូង ចំនួនអ្នកប្រើប្រាស់គឺ ៤-១៣៦ ផ្ទះ (២០-៦៨០នាក់) សំរាប់ស្នប់បូមដៃមួយ (មើលតារាង ៨.៧) ។

ដើម្បីធ្វើឱ្យតំលៃគំរោងមានចំនួនអប្បបរិមា ចំនួនស្នប់បូមដៃកាន់តែតិច គឺត្រូវបានគេត្រូវការ ហើយមានសារៈសំខាន់ក្នុងការចុះឈ្មោះអ្នកប្រើប្រាស់ប៉ុន្មាននាក់នៅក្នុងភូមិតាមរយៈការអប់រំ **O & M**។ ដូច្នេះមនុស្សចំនួន ២១០នាក់ សំរាប់ស្នប់បូមដៃមួយត្រូវបានគេអនុម័យជាបទដ្ឋាមួយ ដើម្បីគណនាអំពីចំនួននៃស្នប់បូមដៃតាមតំរូវការ ដែលមានបង្ហាញនៅក្នុងតារាង ៨.៨។ ចំនួនត្រូវបានគេដករួចហើយនូវចំនួនស្នប់បូមដៃដែលមានស្រាប់ ហើយស្នប់បូមដៃដែលបានដំឡើងនៅក្នុងការសិក្សា។ ចំនួនស្នប់បូមដៃលំអិតសំរាប់ភូមិជាមុខព្រួញមានបង្ហាញនៅក្នុងតារាង ៨.៨ ។

## តារាង ៨.៥ ចំនួនស្នប់បូមដៃដែលត្រូវការ

| កំរិត | ចំនួនភូមិ | ២០០៥ | |
|---|---|---|---|
| | | ចំនួនប្រជាជន | ចំនួនអណ្តូងស្នប់ដែលត្រូវការ |
| **A** | ២៨ | ២២,៦៨៤ | ១២១ |
| **B** | ៥៥ | ៤៤,៧៧៧ | ២៣៦ |
| **C** | ២០ | ២២,៩៣១ | ៦៩ |
| **D** | ២៨ | ២៧,៩២៨ | ១០០ |
| សរុប | ១៣១ | ១១៨,៣២០ | ៥២៦ |

## ៨.៤ បរិក្ខារផ្គត់ផ្គង់

ប្រព័ន្ធផ្គត់ផ្គង់ទឹកនឹងត្រូវបង្កើតឡើងដោយអណ្តូងដែលប្រើបំពង់ទឹប ( អណ្តូងជ្រៅ) ដោយមានស្នប់ដៃ Afridev ទីធ្លាជុំវិញ ហើយនិងឧបករណ៍សំរាប់យកជាតិដែកចេញ (សូមមើលលេខ ៦.២.១ ៦.២.២ និង ៦.២.៣)។ យោងតាមជំពូក ៦.២ បរិក្ខាផ្គត់ផ្គង់ទឹក ហើយនិងលទ្ធផលនៃការសិក្សាគំរោងនៃបរិក្ខារផ្គត់ផ្គង់ទឹកសំរាប់ការអនុវតន្ត៏ មានដូចតទៅ :

### (១) អណ្តូងជ្រៅ

ប្រព័ន្ធផ្គត់ផ្គង់ទឹកនឹងបង្កើតឡើងដោយអណ្តូងដែលប្រើបំពង់ទឹបអណ្តូងជ្រៅដែលចងបាន គឺ ៥០ម៉ែត្រ។ ដោយពិចារណាអំពីសម្ពាធទឹក និងដីនៅជម្រៅ ៥០ម៉ែត្រ ទុយោ PVC អាចប្រើប្រាស់បានដោយលក្ខណៈសន្សំសំចៃ ហើយច្រេះក៏មិនស៊ីទៀត។ ប្លង់នៃការស្ថាបនាអណ្តូងត្រូវបានបង្ហាញនៅក្នុងលេខ ៨.៣។ ទាំងវិធីបារភក់ ទាំងវិធីបញ្ចុះរណ្តៅ (វិទ្ធ DTH) ត្រូវបានចាក់ចូលជាការងារខួង។ ដោយយោលទៅលើកម្លាំងបូមរបស់ស្នប់ Afidev អត្រានៃការបូមរបស់អណ្តូងត្រូវបានគេគិតទុកថាជាង ២០លីត្រ / នាទី។ ក្នុងខណៈពេលដែលពុំមានបទដ្ឋានគុណភាពទឹក នៅកម្ពុជា តម្លៃនៃការណែនាំរបស់អង្គការ WHO នឹងត្រូវបានគេចាត់ទុកជាបទដ្ឋានគុណភាពទឹក។

ទំហំលូ និងផ្ទៃមុខលូ គឺដូចអណ្តូងគំរូ ដូចខាងក្រោម :

- អង្កត់ផ្ចិត ៤អ៊ីង
- ប្រវែងបណ្តោយអណ្តូង ១៦ម៉ែត្រ
- បើកអនុបាត ៥%

### (២) ស្នប់ដៃ

យោងតាមការប្រៀបធៀបនៃស្នប់ដៃសំរាប់ការសិក្សាផកពិសោធន៏ដូចមានរៀបរាប់នៅក្នុងជំពូក ៦.២ ស្នប់ Afridev ត្រូវបានគេទទួលយកសំរាប់ការអនុវត្ត ដោយសំដៅទៅលើគុណសម្បត្តិផ្នែកការថែទាំដ៏ងាយស្រួលផ្នែក

សេដ្ឋកិច្ច និងអនុសាសន៍ MRD ។ ដោយពិចារណាអំពីការដែលច្រេះស៊ីក្នុងពេលអនាគត វត្ថុដែលច្រេះមិនស៊ី គឺបំពង់ ទុយោបញ្ជៀរ និងស្នប់ដូចខាងក្រោមនេះ :

បំពង់ Riser : PVC

ដងស្នប់ : ដែកថែបគ្មានច្រេះចាប់

## (៣) បរិមាណអណ្តូង (Platform)

បង់របស់បរិមាណអណ្តូងមានបង្ហាញនៅក្នុងរូបភាព ៨.៣។ យថាប្រភេទនៃប្លង់របស់បរិវេណអណ្តូង គឺមានរៀបជាប្លង់ដូចខាងក្រោមនេះ :

- ទីលានប្លង់ : អប្បបរិមា 35 cm ខ្ពស់ជាងដី
- រចនាសម្ព័ន្ធ : បេតុងសុទ្ធ
- ទំហំខាងក្នុង : ទទឹង 2.5m x បណ្តោយ 3.8m
- ទំហំចាក់ : ប៉ាតកំរាស់ 15 cm កំរាស់ជញ្ជាំង 15cm
- កំលាំងសង្កត់របស់បេតុង : 21 N / mm$^2$ ( បន្ទះសាកល្បងស៊ីឡាំង)
- ដែកថែប : របាមូលដែលមានអង្កត់ផ្ចិត 9m @ 15 cm x 15 cm

ដើម្បីជៀសវាងពីឥទ្ធិពលនៃទឹកជំនន់ទៅអនាគត កំពស់ទីលានប្លង់នឹងត្រូវកំណត់ ត្រូវលើសពីកំរិតទឹកជំនន់ដែលឡើងដល់កន្លែងរស់នៅរបស់អ្នកភូមិ ។ យកល្អទីលានប្លង់គួរតែធ្វើឡើងដោយអ្នកភូមិនៅទីនោះ ។

## (៤) ការបង្ហូរចេញ

ប្លង់បង្ហូរទឹកចេញមានបង្ហាញនៅក្នុងរូបភាព ៨.៣ ។
យថាប្រភេទនៃប្លង់ គឺត្រូវរាបដូចខាងក្រោម :

- រចនាសម្ព័ន្ធ : បេតុងសុទ្ធ
- ទំហំខាងក្នុង : ទទឹង 35 cm x ជំរៅ 20 cm x បណ្តោយ 5.0 m
- ទំហំចាក់ : ប៉ាតកំរាស់ 15 cm កំរាស់ជញ្ជាំង 15 cm

- យថាប្រភេទនៃបេតុង និងដែកថែបនឹងមានលក្ខណៈដូចបួងទីលានអណ្តូង ។

ការអប់រំអំពីអនាម័យ និង O & M នឹងតំរូវឱ្យអ្នកភូមិទាំងឡាយយល់ដឹងអំពីការការពារដំណើរបង្ហូរទឹក និង សេឌីម៉ង់សំរាម និងជីកលុងស្អាមភ្លោះ ដើម្បីបង្ហូរទឹក ។

### (៥) ឧបករណ៍ជាតិដែកចេញ (IRD)

ដោយយោលទៅតាមហេតុផលបន្តបន្ទាប់ គេចាំបាច់ត្រូវអប់រំអ្នកប្រើប្រាស់អំពីករណីប្រសិទ្ធភាពរបស់ IRD អំពីរបៀបត្រូវដំឡើង និងថែទាំ IRD ។ល ។ ដូច្នេះអ្នកប្រើប្រាស់ត្រូវដំឡើងដោយខ្លួនឯងតាមការចំណាយផ្ទាល់ខ្លួន ។

- ដូចមានបង្ហាញនៅក្នុងជំពូក ៨.២ តំបន់ដែលជាកន្លែងដែលគេមិនសង្ឃឹមថា មានគុណភាពទឹកក្រោមដីល្អ ត្រូវ បានគេដកចេញពីតំបន់មុខព្រួញក្នុងការអនុវត្ត ។ ចំនួនអណ្តូងដែលមានជាតិកំហាប់ដែកខ្ពស់ ក៏គេសង្ឃឹមតិចដែរ ។
- ដោយយោលទៅតាមរបាយការណ៍ត្រួតពិនិត្យបន្តបន្ទាប់ (II) ការសិក្សាអំពីការអភិវឌ្ឍន៍ទឹកក្រោមដីនៅក្នុង ប្រទេសកម្ពុជាភាគខាងត្បូង (ខែធ្នូ ឆ្នាំ២០០១, JICA ) ប្រសិនបើមានប្រភពទឹកឆ្លាស់មួយគួបផ្សំនឹងគុណភាព ទឹក ប្រសើរជាងអណ្តូង បន្ទាប់មកអ្នកភូមិមិនចាំបាច់ប្រើឧបករណ៍នេះឡើយ ទោះបីជា IRD មានឥទ្ធិពលល្អក្នុង ការកាត់បន្ថយជាតិដែកក៏ដោយ ។ ដូច្នេះហើយ IRD នឹងត្រូវគេដំឡើង អាស្រ័យទៅលើសេចក្តីស្នើសុំរបស់អ្នក ប្រើប្រាស់បន្ទាប់ពីបញ្ចប់អណ្តូងស្នប់ដៃដំពេញលេញមក ។
- ឧបករណ៍ដកជាតិដែកចេញ ត្រូវបានគេដំឡើងក្នុងពេលសិក្សា ។ គំរូនោះ គឺតំលៃប្រហែល ១០០០ដុល្លារអាមេរិក ពីព្រោះវាធ្វើអំពីដែកថែប ។ ទោះជាយ៉ាងណាក៏ដោយ តំលៃអាចកាត់បន្ថយបានដោយការសាងសង់តាមគំរូតែ មួយជាមួយបេតុង ។ ប្រសិនបើបួងមួយមានតំលៃថោក និងងាយស្រួលក្នុងការសង់ នោះអ្នកប្រើប្រាស់អាចសង់ ឧបករណ៍ដោយខ្លួនឯង ។

## ៨.៥ តំលៃគំរោង

### ៨.៥.១ លក្ខខណ្ឌនៃការប៉ាន់ស្មាន

តំលៃគំរោងត្រូវបានគិតទៅតាមលក្ខណ្ឌដូចខាងក្រោម :

- ពេលវេលានៃការប៉ាន់ស្មាន : ខែកុម្ភៈ ឆ្នាំ២០០២
- អត្រាដូរប្រាក់ : ១ដុល្លារអាមេរិក = ៣៩១០ រៀល = ១៣៣ យ៉េន
- រយៈពេលអនុវត្តន៏ : ៧២ខែ
- អ្នកម៉ៅការ : អ្នកម៉ៅការ និងទីប្រឹក្សាកម្ពុជា
- អ្នកម៉ៅការបន្តពីការងារខួង : ប្រទេសទីបី
- អត្រារន្ទស្ទួច : ២០%

អត្រារន្ទស្ទួតពិតប្រាកដពីការខួងសាកល្បងនៅក្នុងការសិក្សាស្រាវជ្រាវ គឺ ១៧% នៅក្នុងខេត្តកំពង់ចាម អត្ថន័យនៃតំលៃគំរោង គឺមានដូចខាងក្រោម :

## (១) ការកសាងបរិក្ខារផ្គត់ផ្គង់ទឹក

ក- ការសាងសង់អណ្តូងជ្រៅ : ចំនួន៥២៦

## (២) ឧបករណ៍នាំមកឱ្យសំរាប់ដំណើរការ និងការថែទាំ

ក- គ្រឿងបន្លាស់ Afridev : ចំនួន ២៥០
ខ- ឧបករណ៍ថែទាំ Afridev : ចំនួន ៥៣
គ- ឧបករណ៍ផ្គុំស្នប់បូមដៃ : ចំនួន ៥៣
ឃ- រថយន្ត Pickup : ចំនួន ២
ង- ឧបករណ៍សម្អាតខ្យល់ : ចំនួន ១
ច- រថយន្តស្ទួច : ចំនួន ១

តំលៃគំរោងមានបង្ហាញនៅក្នុងតារាង ៨.៦ ។

## (៣) ការគ្រប់គ្រងម្ហូប

ក/ ប្លង់លំអិត និងការស្នើសុំជាផ្លូវការ

ខ/ ការគ្រប់គ្រងការសាងសង់

គ/ ការរៀបចំ / អនាម័យ / ការគ្រប់គ្រងកម្មវិធី O & M

ឃ/ ត្រួតពិនិត្យការគ្រប់គ្រង

តំលៃគំរោងត្រូវបានបង្ហាញនៅក្នុងតារាង ៨.៦ ។

តារាង ៨.៦ តំលៃ

| កម្មវត្ថុ | ចំនួន |
|---|---|
| ចំនួនសរុប | ១១,៩១៣ |
| ១ សំណង់ស៊ីវិល | ១០,៣៧៥ |
| ១-១ តំលៃសំណង់ | ៩,៤៣២ |
| ក. តំលៃផ្ទាល់ | ៨,៤២៤ |
| ខ. តំលៃប្រយោល | ២៥៧ |
| គ. ការចំណាយផ្ទាល់ | ៧៥១ |
| ១-២ ប្រាក់ចំណាយជាទូទៅ | ៩៤៣ |
| ២ ឧបករណ៍ដែលផ្គត់ផ្គង់ | ២០៥ |
| ១-២ តំលៃឧបករណ៍ | ១៧៧ |
| ២-២ តំលៃដឹកជញ្ជូន | ២១ |
| ២-៣ ប្រាក់ចំណាយជាទូទៅ | ៦ |
| ៣ ប្លង់ និងការគ្រប់គ្រង | ១,៣៣៣ |
| ៣-១ ប្លង់ | ២៩៣ |
| ក. ចំណាយផ្ទាល់ | ១៣៨ |
| ខ. ចំណាយសំរាប់បុគ្គលិក | ៦៤ |
| គ. ចំណាយជាប្រយោល | ៩០ |

| | |
|---|---|
| ៣-២ ការគ្រប់គ្រង | ៤០២ |
| ក. ចំណាយផ្ទាល់ | ១៩៦ |
| ខ. ចំណាយបុគ្គលិក | ៨៦ |
| គ. ចំណាយប្រយោល | ១២០ |
| ៣-៣ ការអប់រំ និងការត្រួតពិនិត្យ | ៦៣៨ |
| ក. ចំណាយផ្ទាល់ | ២៥០ |
| ខ. ចំណាយបុគ្គលិក | ១៦២ |
| គ. ចំណាយប្រយោល | ២២៧ |

តំលៃគំរោងតាមវគ្គក៏បានគណនា និងបង្ហាញនៅក្នុងតារាង ៨.៧ ។

តារាង ៨.៧ តំលៃគំរោងតាមវគ្គ

| វគ្គ | I | II | III | សរុប |
|---|---|---|---|---|
| ឆ្នាំ | 2003~2005 | 2004~2007 | 2006~2008 | |
| ភូមិមុខព្រួញ | A | B | C+D | |
| ចំនួនភូមិ | ២៨ | ៥៥ | ៤៨ | ១៣១ |
| ចំនួនអណ្តូងជ្រៅ និង អណ្តូងស្នប់បូមដៃ | ១២១ | ២៣៦ | ១៦៩ | ៥២៦ |
| តំលៃសាងសង់ | ២,៤២៦ | ៤,៦៧៤ | ៣,២៧៥ | ១០,៣៧៥ |
| ឧបករណ៏ និង សំភារៈនាំមកអោយ | ១៧៤ | ២៥ | ៦ | ២០៥ |
| តំលៃគ្រប់គ្រងបួង់ | ៣៩៣ | ៥៤៨ | ៣៩២ | ១,៣៣៣ |
| សរុប | ២,៩៩៣ | ៥,២៤៧ | ៣,៦៧២ | ១១,៩១៣ |

## ៨.៦ ការអនុវត្តគំរោង

### ៨.៦.១ អង្គភាពអនុវត្តន៍

ទីភ្នាក់ងារនានាទទួលបន្ទុកខាងអនុវត្តន៍គំរោង គឺ DRWS របស់ MRD និងនាយកដ្ឋានអភិវឌ្ឍន៍ជនបទខេត្ត (RDRD) នៅក្នុងខេត្តកំពង់ចាមដែលពាក់ព័ន្ធ។ សំរាប់ការអនុវត្តន៍ប្រកបដោយដំណើរការល្អ និងមានប្រសិទ្ធភាពចំពោះគំរោងអង្គភាពគ្រប់គ្រងគំរោង (PMU) នឹងត្រូវបានគេបង្កើតឡើងនៅឯទីបញ្ជាការរបស់ DRWS ។ ដោយមានកិច្ចសហប្រតិបត្តិការរបស់ទីប្រឹក្សា PMU នឹងគ្រប់គ្រងគំរោង។ ស្របជាមួយប្លង់លំអិត ទីប្រឹក្សានឹងពង្រីកគោលការណ៍ណែនាំផងដែរ នៅក្នុងការបង្កើត WPC មួយនៅក្នុងភូមិជាមុខព្រួញ និង O & M លើបរិក្ខារព្រមទាំងដឹកនាំយុទ្ធនាការអនាម័យមួយ និងការបណ្តុះបណ្តាលអំពី O & M បន្ទាប់ពីការដំឡើងស្នប់បូមដៃ។ ជាមួយគ្នានេះដែរ ទីប្រឹក្សាដឹកនាំការត្រួតពិនិត្យជាមួយ PDRD ស្ដីអំពី O & M សំរាប់បរិក្ខារផ្គត់ផ្គង់ទឹករយៈពេលមួយឆ្នាំ បន្ទាប់ពីការសាងសង់ចប់សព្វគ្រប់។ អ្នកម៉ៅការ និងកសាងបរិក្ខារផ្គត់ផ្គង់ទឹក ឧបករណ៍ចាំបាច់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីប្រឹក្សាពិគ្រោះ។

### ៨.៦.២ កាលវិភាគអនុវត្តន៍

កាលវិភាគសំរាប់ការអនុវត្តន៍ផែនការផ្គត់ផ្គង់ទឹក គឺធ្វើឡើងស្របទៅតាមគោលនយោបាយរៀបចំផែនការ ជាមូលដ្ឋាន និងមានបង្ហាញនៅក្នុងរូប ៨.៤ ។

## ៨.៧ ដំណើរការ និងថែទាំ និងត្រួតពិនិត្យកម្មវិធី

### ៨.៧.១ គោលការណ៍ O & M

ទស្សនៈ VLOM នឹងត្រូវគេអនុម័តសំរាប់ O & M បរិក្ខារផ្គត់ផ្គង់ទឹក។ ដើម្បីធ្វើករណីនេះបានស្នប់បូមដៃ Afridev មួយនឹងត្រូវបានគេបង្កើតឡើង។ ការត្រួតពិនិត្យអំពីស្នប់បូមដៃប្រចាំថ្ងៃនៅថ្នាក់ភូមិ គឺអាចធ្វើទៅបានតាមរយៈការបង្កើត WPC ។ ដោយសារស្នប់បូមដៃ Afridev ងាយស្រួលប្រៀបធៀបចំពោះការរុះរើ និងរៀបចំផ្គុំឡើងវិញ ការបណ្តុះបណ្តាលដល់អ្នកភូមិនានានឹងអាចធ្វើឱ្យពួកគេអនុវត្តនូវការជួសជុលតូចតាច។ ជាមួយនឹង

ផ្នត់គំនិតនេះ គំរោងមានបំណងឱ្យគេជួសជុលនូវការខូចខាតតិចតួចដោយ WPC ដែលជាអ្នកនឹងត្រូវរក្សាទុកឧបករណ៍ដែលត្រូវការ ។ ទាក់ទងនឹងបញ្ហានេះ VWC នឹងរក្សាការទាក់ទង និងសម្របសម្រួលជល់ផ្នែកផ្គត់ផ្គង់ទឹកជនបទរបស់ PDRD និង WPC ។ ជាងនេះទៀត ផ្នែកនេះនឹងមិនគ្រាន់តែទិញ និងរក្សាទុកគ្រឿងបន្លាស់ប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ត្រូវ ទាក់ទងតំលៃជួសជុលស្នប់បូមដៃសំខាន់ៗ ។ DRWS នឹងអនុវត្តនីនូវការស្តារអណ្តូងឡើងវិញ (ដូចជាលាងអណ្តូង) រៀបចំផែនការផ្គត់ផ្គង់ទឹក ការបង្កើតបទដ្ឋានបួង់ គោលការណ៍ណែនាំអំពីបច្ចេកទេស ព្រមទាំងការកសាងបរិក្ខារផ្គត់ផ្គង់ទឹក និងការបង្កើតបទដ្ឋានបួង់ ។ ការកសាងបរិក្ខារផ្គត់ផ្គង់ទឹកដោយប្រើគ្រឿងម៉ាស៊ីនសមស្រប និងការជាវ (ជាដុំ) ការស្តុកទុក និងការចែកចាយគ្រឿងបន្លាស់ នឹងត្រូវបានគេអនុវត្តន៍ទៅតាមការពិចារណានៃសំណើរបស់ BDRD (ចូរមើលរូប ៨.៥) ។



## ៨.៧.២ ប្រព័ន្ធប្រតិបត្តិ និងការថែទាំ (O & M)

### (១) ថ្នាក់ភូមិ

អ្នកថែរក្សាអណ្តូងម្នាក់ និងហេរញ្ញិកនឹងត្រូវបានគេចាត់តាំងក្នុងចំណោមសមាជិក WPC ដែលនឹងបង្កើតជាអ្នកប្រើប្រាស់អណ្តូង។ ស្ថិតនៅក្រោមគោលការណ៍ណែនាំ និងសេចក្តីណែនាំអំពីប្រធានគណៈកម្មាធិការ អ្នកប្រើប្រាស់នឹងត្រូវបង់ថ្លៃទឹកសំរាប់ការប្រើប្រាស់អណ្តូង រក្សាអណ្តូងឱ្យស្អាតនៅជុំវិញ និងដឹកនាំការត្រួតពិនិត្យប្រចាំថ្ងៃ។ អ្នកថែទាំនឹងទទួលបន្ទុកត្រួតពិនិត្យប្រចាំថ្ងៃដាក់គ្រឿងបន្លាស់ ព្រមទំាំងជួសជុលតូចតាច។ ហេរញ្ញិកនឹងត្រូវប្រមូល និងគ្រប់គ្រងថ្លៃទឹក ដែលនឹងត្រូវប្រើប្រាស់ដើម្បីគ្របដណ្តប់លើការចំណាយ សំរាប់ការថែទាំទៀងទាត់ជួសជុល និងការទិញគ្រឿងបន្លាស់។

### (២) ថ្នាក់ខេត្ត

ក្រុមជំនួយការមួយនឹងត្រូវបានគេរៀបចំនៅក្នុងផ្នែកផ្គត់ផ្គង់ទឹកនៅជនបទរបស់ PDRD ដើម្បីត្រួតពិនិត្យបរិក្ខារ និងគ្រប់គ្រងការខូចខាតរបស់ស្នប់បូមដៃដែលអ្នកភូមិមិនអាចដោះស្រាយបាន។ ក្រុមនេះនឹងបង្កើត ពីសមាជិកជាបុគ្គលិកពេញម៉ោង បំពាក់ឧបករណ៍ដោយយានយន្ត ឧបករណ៍សំភារៈ និងគ្រឿងផ្សេងៗ សំរាប់អនុវត្តការជួសជុលស្នប់បូមដៃដែលស្នើសុំដោយអ្នកភូមិនានា។

## ៨.៧.៣ តំលៃនៃការប្រតិបត្តិ និងការថែទាំ

តំលៃប្រតិបត្តិ និងការថែទាំប្រចាំឆ្នាំនៅថ្នាក់ភូមិ ត្រូវបានប៉ាន់ស្មានទៅតាមការពិចារណាពីតំលៃគ្រឿង បន្លាស់ពេលចុះធ្វើការត្រួតពិនិត្យរបស់ PDRD ដែលធ្វើឡើងម្តងក្នុងមួយឆ្នាំប្រែងឥន្ធនៈ និងប្រាក់ឧបត្ថម្ភសំរាប់ឧបការី PDRD ជួសជុលយ៉ាងរូសរាន់សំរាប់មួយ (១) ថ្ងៃ។ ជាងនេះទៅទៀត ដើម្បីជំនួសឡើងវិញនូវគ្រឿងស្នប់បូមដៃ មួយក្នុងរយៈពេលដប់ (១០) ឆ្នាំ តំលៃស្នប់បូមដៃមួយកំប្លេថ្មី គឺ ១៦០ដុល្លារត្រូវដាក់ជាតំលៃ O & M ប្រចាំឆ្នាំ។ លើសពីនេះទៀត ការអភិវឌ្ឍន៍អណ្តូងត្រូវបានគេពិចារណានូវការងារចាំបាច់សំរាប់ O & M ដែលត្រូវធ្វើបី(៣)ឆ្នាំម្តង។ តំលៃប្រចាំឆ្នាំសំរាប់ការអភិវឌ្ឍន៍អណ្តូងត្រូវបានគេប៉ាន់ស្មានមានចំនួន ៤៨ ដុល្លារអាមេរិក។

ចំនួនសរុបនៃតំលៃ O & M ត្រូវបានប៉ាន់ស្មាន គឺមាន ១៣២ដុល្លារអាមេរិកប្រចាំឆ្នាំ។ តំលៃដ៏ចាំបាច់អស់ទាំងនេះនឹងត្រូវកើនឡើងតាមអ្នកប្រើប្រាស់ប្រចាំឆ្នាំ។ ដោយយោលទៅតាមជំពូក ៨.៣ អ្នកទទួលផលដែលបានប៉ាន់ស្មានប្រចាំឆ្នាំសំរាប់មួយគ្រួសារ (ប៉ាន់ស្មានគ្រួសារដែលមានសមាជិក ៥នាក់) គឺ ៣ដុល្លារអាមេរិកនៅក្នុងតារាងខាង ក្រោម :

តារាង ៨.១៨ តំលៃ O & M ប្រចាំឆ្នាំនៅថ្នាក់ភូមិ

| | ពិពណ៌នា | ថ្លៃឯកតា (ដុល្លារអាមេរិក) | បរិមាណ | សរុប (ដុល្លារអាមេរិក) | កំណត់សំគាល់ |
|---|---|---|---|---|---|
| ១. | ដាក់គ្រឿងបន្លាស់ថ្មី | ១១,០ | ១ គ្រឿង | ១១,០ | រាល់ឆ្នាំ |
| ២. | ប្រាក់ឧបត្ថម្ភបុគ្គលិក MPRD | ៥,០ | ២ នាក់ | ១០,០ | ត្រួតពិនិត្យប្រចាំឆ្នាំ |
| ៣. | ឡានត្រួតពិនិត្យ | ២៥,០ | ១ ថ្ងៃ | ២៥,០ | Ditto |
| ៤. | អភិវឌ្ឍន៍អណ្តូង | ១៦០,០ | ០,៣ ដង | ៤៨,០ | រៀងរាល់បីឆ្នាំ |
| ៥. | ប្រាក់ឧបត្ថម្ភបុគ្គលិក DRWS | ១៥,០ | ០,៦ នាក់ | ៩,០ | Ditto |
| ៦. | ឡានចុះត្រួតពិនិត្យ | ២៥,០ | ០,៣ ថ្ងៃ | ៧,៥ | Ditto |
| ៧. | ដាក់ស្នប់បូមដៃថ្មី | ១៦០,០ | ០,១ គ្រឿង | ១៦០,០ | រៀងរាល់១០ឆ្នាំ |
| ៨. | ប្រាក់ឧបត្ថម្ភបុគ្គលិក DRWS | ១៥,០ | ០,២ នាក់ | ៣,០ | Ditto |
| ៩. | ឡានចុះត្រួតពិនិត្យ | ២៥,០ | ០,១ ថ្ងៃ | ២,៥ | Ditto |
| | សរុប | | | ១៣២,០ | |

**អត្រាប្តូរប្រាក់ : ១ ដុល្លារអាមេរិក ≈ ៣៩៦០ រៀល ≈ ១៣៣ យ៉េន**

ក្នុងចំណោមភូមិចំនួន ២០ ដែលបានបង្ហាញនៅលើ “ ការសិក្សាដំណើរការអភិវឌ្ឍន៍ទឹកក្រោមដីនៅក្នុងប្រទេសកម្ពុជាភាគខាងត្បូង ” អត្រានៃការប្រមូលបានតំលៃទឹក គឺមានតែ ៣៥% ប៉ុណ្ណោះ។ នៅពេលដែលគេសួរថាហេតុអ្វីនៅក្នុងពេលកំពុងធ្វើបទសំភាសន៍នោះ ការឆ្លើយតបនានា គឺថា “ ទោះបីជាតំលៃថ្លៃឈ្នួលត្រូវបានគេប្រមូលមែន តែមិនមានគណនីសុវត្ថិភាព រឺ ប្រអប់សុវត្ថិភាព ត្រូវទុកលុយនោះនៅក្នុងឡើយ ” ហើយ “

តំលៃឈ្នួលនេះនឹង ត្រូវបានប្រមូលនៅពេលគេត្រូវការ និងការជួសជុល "។ វិធីសាស្ត្រមួយសំរាប់ការប្រមូល គំរូវឱ្យគេត្រួតពិនិត្យសំរាប់ ភូមិនីមួយៗ ដោយពឹងផ្អែកទៅលើស្ថានភាពថ្មីនីមួយៗ។

## ៨.៧.៤ កម្មវិធីត្រួតពិនិត្យ

ដើម្បីយល់អំពីការប្រើប្រាស់ជានិរន្តភាពនៃគ្រឿងបរិក្ខារ ការត្រួតពិនិត្យតាមឱកាសទៅលើបរិក្ខារ និងការប្រតិបត្តិ O & M គំរូវឱ្យគេដឹកនាំចុះពិនិត្យលើបញ្ហានានា ហើយបរិក្ខារក៏គំរូវគេថែទាំឱ្យបានល្អដែរ។

### (១) ការអនុវត្តន៍លើការត្រួតពិនិត្យ

ការត្រួតពិនិត្យសកម្មភាពនានា គួរតែត្រូវធ្វើឡើងក្នុងរយៈពេលយូរអង្វែង និងការិយាល័យផ្គត់ផ្គង់ទឹកជនបទ និងការិយាល័យអភិវឌ្ឍន៍សហគមន៍របស់ PDRD ដែលមានយុត្តាធិការនៅលើតំបន់ដែលជាមុខព្រួញ គួរតែជាស្ថាប័នទទួលខុសត្រូវមួយ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារបុគ្គលិករបស់ PDRD មិនមានបទពិសោធន៍ និងមិនស្គាល់ពីរបៀបធ្វើនោះ ការត្រួតពិនិត្យក្នុងឆ្នាំទីមួយបន្ទាប់ពីការកសាងបរិក្ខាររួមមក គួរតែរាប់បញ្ចូលទៅជាផ្នែកមួយនៃគំរោង។ នៅក្នុងរយៈពេលនោះបុគ្គលិក PDRD គួរត្រូវគេផ្តល់ឱ្យនូវការបណ្តុះបណ្តាលបច្ចេកទេស ដើម្បីរៀបចំជាមួយមុខជំនាញចាំបាច់ ក្នុងការបន្តការត្រួតពិនិត្យដ៏មានប្រសិទ្ធភាព នៅពេលដែលគំរោងចប់សព្វគ្រប់។

ជាងនេះទៅទៀត រថយន្តធុន 4WD (Pickup) ចំនួនពីគ្រឿងនឹងត្រូវប្រគ្រុយត្រួតពិនិត្យមើលសកម្មភាពជាផ្នែកមួយរបស់គំរោង ព្រោះផ្នែកអភិវឌ្ឍន៍ជនបទមិនអាចលែកធ្វើការងារនេះបានឡើយ។

### (២) វិធីសាស្ត្រនៃការត្រួតពិនិត្យ

សមាជិកជាបុគ្គលិករបស់ PDRD ចំនួនពីរនាក់ (ម្នាក់ទទួលបន្ទុកផ្នែកបរិក្ខារផ្គត់ផ្គង់ទឹក និងម្នាក់ទៀតទទួលបន្ទុកខាងអង្គការសហគមន៍) រួមគ្នាជាមួយ WPL និង VWC គួរតែត្រូវដឹកនាំសកម្មភាពត្រួតពិនិត្យ ដូចមានក្នុងបញ្ជីខាងក្រោម។ ការត្រួតពិនិត្យគួរតែត្រូវដឹកនាំធ្វើប្រចាំឆ្នាំសំរាប់ភូមិនីមួយៗ។

① បរិក្ខារផ្គត់ផ្គង់ទឹក គួរតែត្រូវគេចុះត្រួតពិនិត្យ ហើយប្រសិនបើមានផ្នែកណាមួយខូចខាតដែលគេរកឃើញពួកគេគួរតែត្រូវជួសជុលភ្លាមៗ។ បុព្វហេតុ និងហេតុផលសំរាប់ការពន្យារពេលជួសជុលគួរតែត្រូវកំណត់ផងដែរ។

②គេគួរតែអះអាងថា បរិក្ខារទាំងនេះត្រូវបានគេថែទាំគ្រប់ជ្រុងជ្រោយ វី ក៏អត់ ។

③គេគួរតែអះអាងថា ប្រព័ន្ធ O & M ដំណើរការប្រកបដោយធម្មតា វី ក៏អត់

④ដោយពឹងផ្អែកទៅលើលទ្ធផលខាងលើ បញ្ហាដែលត្រូវធ្វើឱ្យប្រសើរ គួរតែត្រូវគេបង្ហាញឱ្យបានច្បាស់ ដល់សមាជិក WPC និង VWC ហើយគោលការណ៍ណែនាំគួរតែត្រូវគេផ្តល់ឱ្យតាមសេចក្តីយោង ។

### (៣) តំលៃត្រួតពិនិត្យ

ដោយសារតែ PDRD មិនមានគំរោងថវិកា អ្នកប្រើប្រាស់ដែលជាអ្នកទទួលផលប្រយោជន៍ គួរតែត្រូវជួយចេញថ្លៃ។ ប្រាក់ឧបត្ថម្ភដល់បុគ្គលិក PDRD និងតំលៃយានយន្តសំរាប់សកម្មភាព បើប្រត្រុយត្រួតពិនិត ត្រូវបានគេធ្វើមួយម្តងមួយក្នុងមួយឆ្នាំ ដូចមានបង្ហាញយ៉ាងត្រឹមត្រូវនូវតំលៃថែទាំក្នុងតារាង ៨.៨។

## ៨.៨ គោលការណ៍ណែនាំនៅក្នុងយុទ្ធនាការអនាម័យ និង O & M

កម្មវិធីអប់រំសុខភាព និង O & M ក៏ជាកត្តាគន្លឹះក្នុងកម្មវិធីផ្គត់ផ្គង់ទឹក។ ដើម្បីសំរេចបាននូវនិរន្តភាពនៃកម្មវិធីនេះ ទីប្រឹក្សាផ្នែកប្រឹក្សានឹងបង្កើតក្រុមមួយ ដោយរួមមានទីប្រឹក្សាផ្នែកប្រឹក្សា DRWS និង PDRD ដើម្បីជំរុញការអប់រំសុខភាព និង O & M។ ទីប្រឹក្សាផ្នែកប្រឹក្សាប្រចាំមូលដ្ឋាននឹងត្រូវគេឱ្យធ្វើការសំរាប់ដំណាក់កាលអនុវត្តន៍ចាប់ពីការចាប់ផ្តើមរហូតដល់មួយ (១) ឆ្នាំ បន្ទាប់ពីការសាងសង់ចប់សព្វគ្រប់។

ភាពលំអិតនៃសកម្មភាពមានដូចខាងក្រោម :

### (១) ពីដំណាក់កាលរៀបចំផែនការ

ក្រុមប្រឹក្សានឹងត្រូវចូលទំនាក់ទំនងសហគមន៍ភូមិតាមរយៈ WPC តាមលក្ខខណ្ឌនៃវិធីសាស្ត្រ ដើម្បីជំរុញការ

អប់រំសុខភាព និង VLOM ។ នៅពេលជាមួយគ្នានេះដែរ មន្ត្រីខេត្តនានានឹងត្រូវគេបណ្តុះបណ្តាលជាដៃគូដ៏ជិតស្និទ្ធបំផុតចំពោះសហគមន៍ភូមិនៅក្នុងផ្នែកសុខភាព និង O & M ។

## (២) នៅក្នុងដំណាក់កាលសាងសង់

ការចូលរួមរបស់សហគមន៍ភូមិ ក្នុងការងារសាងសង់នឹងត្រូវបានគេជំរុញឱ្យមានចំនួនជាអតិបរមា ដែលដឹកនាំភាពជាម្ចាស់របស់ពួកគេចំពោះសហគមន៍នោះ ។ ជាងនេះទៅទៀត សហគមន៍ភូមិនឹងត្រូវគេបណ្តុះបណ្តាលអំពីតំឡើងស្នប់បូមដៃ និងការជួសជុល ការសាងសង់ / ការតំឡើង អំពីបរិក្ខារបន្ទាប់សន្សំ (ដូចជាបឧបករណ៍យកជាតិដែកចេញ) ។

## (៣) បន្ទាប់ពីការងារសាងសង់បញ្ចប់យ៉ាងពេញលេញ

អ្នកទីប្រឹក្សាប្រចាំមូលដ្ឋាននឹងរក្សានូវការត្រួតពិនិត្យសហគមន៍ភូមិ និងមន្ត្រីផ្នែករដ្ឋបាលនានា នៅថ្នាក់ខេត្ត និងថ្នាក់ភូមិ និងការរៀបចំការប្រជុំ រឺ ធ្វើសិក្ខាសាលា ដើម្បីពង្រឹងនូវអ្វីៗ ដែលពួកគេត្រូវដាក់សំរាប់ O & M ប្រសិនបើចាំបាច់ ។ រៀងរាល់ពេលចុះត្រួតពិនិត្យ សហគមន៍ភូមិទីប្រឹក្សាប្រចាំមូលដ្ឋាននឹងត្រូវយោងទៅតាមអ្នកចង្អុលបង្ហាញ ដើម្បីវាស់វែងអំពីសមិទ្ធផលរបស់ពួកគេ និងធ្វើទៅតាមមធ្យោបាយដ៏ប្រសើរល្អតលាស់ ។

## (៤) ការអប់រំសុខភាព និងអនាម័យ

ការអប់រំគុណភាព និងអនាម័យនឹងត្រូវគេធ្វើតាមរយៈដំណាក់កាលទាំងមូលតែម្តង ។ ជាពិសេសផ្នែកអនាម័យនឹងត្រូវគេផ្សព្វផ្សាយទៅដល់សហគមន៍អំពីរបៀបការពារជំងឺ ។

តាមរយៈសកម្មភាពបង្ហាញខាងលើ ការបារម្ភមួយដ៏សំខាន់ គឺត្រូវតែដាស់តឿនក្រេិនរំលឹកពីចំណេះដឹងរបស់សហគមន៍ភូមិ និងបង្កើនសមត្ថភាពរបស់ពួកគេសំរាប់ O & M ។ សមត្ថភាពជួយឧបត្ថម្ភរៀបចំ ដូចជា PDRD និង DRWS នឹងត្រូវបានគេសង់ឱ្យខ្ពស់ជាងគឺរិត ក្នុងពេលដំណាលគ្នានោះ ។




**Figure 8.1 Flow Chart of Village Classification**




# Figure 8.3 Design of Platform and Drain

S=1/40

REMARK
Concrete Strength: 21 N/mm2
Reinforcing Steel Bar: ϕ9mm @ 150mmX150mm
Embankment shall be 35cm higher than ground level




Figure 8.4 Implementation Schedule